**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ស្ពឺ**
សាលក្រមលេខ: ២៣ "ឃ"
ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២
សំណុំរឿងរដ្ឋប្បវេណីលេខ: ៦១
ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកំពង់ស្ពឺ

កាលបរិច្ឆេទនៃការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃអង្គារ ១រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២។

លើសំណុំរឿងរដ្ឋប្បវេណីលេខ: ៦១ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១។

ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រម

**ក្រឡាបញ្ជី**

លោក [redacted] ជាក្រឡាបញ្ជី

**ដើមចោទ**

-ឈ្មោះ [redacted] សល្យ ភេទប្រុស អាយុ៦៧ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ មានទីកន្លែងកំណើតនៅភូមិ [redacted] ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ឪពុកឈ្មោះ [redacted] ស៊ុំ (ស្លាប់) ម្តាយឈ្មោះ [redacted] អ៊ុន (ស្លាប់) ប្រពន្ធឈ្មោះ [redacted] អិត (ស្លាប់) មានកូន ០៦នាក់។

**ចុងចម្លើយ**

-ឈ្មោះ [redacted] ចន្ថន ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ មានទីកន្លែងកំណើតនៅ [redacted] ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ឪពុកឈ្មោះ [redacted] ឈន (រស់) ម្តាយឈ្មោះ [redacted] សឹង (រស់) ប្រពន្ធឈ្មោះ [redacted] សារឿន (រស់) មានកូន ០៣នាក់។

-លោកមេធាវី [redacted] អត្តលេខ ៣៨០, លោកមេធាវី [redacted] អត្តលេខ ១៥៨០ និងលោកមេធាវី [redacted] អត្តលេខ ២២៥២T ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវី នៃក្រុមមេធាវី [redacted] មានការិយាល័យស្ថិតនៅផ្ទះលេខ



Scanned with CamScanner

[redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ចន្ថន។

**អង្គហេតុ និងចំណុចវិវាទ**

**ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖**

១-សុំរំលាយកិច្ចសន្យាទទួលប្រាក់កក់ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ រវាងឈ្មោះ [redacted] សល្យ និងឈ្មោះ [redacted] ចន្ថន។

២-ប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**ខ្លឹមសារនៃបណ្តឹងតបដែលចុងចម្លើយទាមទារឱ្យតុលាការចេញសាលក្រម៖**

១-បង្គាប់ឱ្យដើមចោទអនុវត្តកិច្ចសន្យាទទួលប្រាក់កក់ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ រវាងដើមចោទ និងចុងចម្លើយ។

២-បង្គាប់ឱ្យចុងចម្លើយធ្វើការទូទាត់ប្រាក់ថ្លៃដីដែលនៅសល់ចំនួន ៦៤.៣៥០ (ប្រាំមួយម៉ឺនបួនពាន់បីរយហាសិប) ដុល្លារអាមេរិក ឱ្យទៅភាគីដើមចោទ។

៣-បង្គាប់ឱ្យដើមចោទបន្ត និងអនុវត្តទៅតាមនីតិវិធីសុរិយោដីផ្ទេរកម្មសិទ្ធិ មានក្បាលដីលេខៈ ២១១៥ ដែលមានទំហំ ៤.៦៩០ (បួនពាន់ប្រាំមួយរយកៅសិប) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិត្រពាំងសុភី ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ មកឱ្យចុងចម្លើយ។

**ការពន្យល់គ្រួសៗអំពីរឿងក្តី**

កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ ដើមចោទឈ្មោះ [redacted] សល្យ បានលក់ដីមួយកន្លែង ទំហំ ៤.៦៩០ (បួនពាន់ប្រាំមួយរយកៅសិប) ម៉ែត្រការ៉េ ដែលមានទីតាំងស្ថិតនៅភូមិត្រពាំងសុភី ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ក្នុងមួយម៉ែត្រការ៉េ តម្លៃ ១៥ (ដប់ប្រាំ) ដុល្លារអាមេរិក ទៅឱ្យចុងចម្លើយឈ្មោះ [redacted] ចន្ថន ដោយធ្វើកិច្ចសន្យាទទួលប្រាក់កក់ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ ទុកជាឯកសារ។ នៅថ្ងៃចុះកិច្ចសន្យានោះដែរ ចុងចម្លើយឈ្មោះ [redacted] ចន្ថន បានកក់ប្រាក់ថ្លៃដីមកឱ្យដើមចោទចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាមេរិក ចំណែកប្រាក់ដែលនៅសល់ ដើមចោទ និងចុងចម្លើយសន្យាគ្នាប្រគល់ប្រាក់ឱ្យគ្រប់ចំនួនមិនឱ្យហួសថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ ឡើយ។ លុះដល់កាលកំណត់ទូទាត់ប្រាក់ថ្លៃដី ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ ចុងចម្លើយមិនបានយកប្រាក់មកទូទាត់ឱ្យដើមចោទទេ ហើយក៏មិនបានជូនដំណឹងមកឱ្យដើមចោទឡើយ។ រហូតមកដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ដើមចោទបានជម្រាបជូនទៅលោកមេឃុំភ្នំតូច អំពីរឿងកក់ប្រាក់ថ្លៃដីរបស់ដើមចោទ និងចុងចម្លើយឈ្មោះ [redacted] ចន្ថន ហើយលោកមេឃុំបានជូនដំណឹងទៅចុងចម្លើយ ដើម្បីឱ្យចូលខ្លួនមកដោះស្រាយ ហើយចុងចម្លើយក៏បានព្រមព្រៀងបញ្ចប់កិច្ចសន្យានេះជាអសារបង់ ប៉ុន្តែចុងចម្លើយមិនព្រមផ្តិតស្នាមមេដៃលើកំណត់ហេតុនោះឡើយ ទើបដើមចោទដាក់ពាក្យបណ្តឹងសុំរំលាយកិច្ចសន្យាខាងលើនេះ។

**ការអះអាងរបស់ភាគី**

-ដើមចោទឈ្មោះ [redacted] សល្យ បានធ្វើសេចក្តីថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា: កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ ខ្ញុំបាទបានព្រមព្រៀងលក់ដីមួយកន្លែងមានទំហំ ៤.៦៩០ (បួនពាន់ប្រាំមួយរយកៅសិប) ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រពាំងសុភី ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ឱ្យទៅចុងចម្លើយឈ្មោះ [redacted] ចន្ថន ក្នុងតម្លៃ ០១ (មួយ) ម៉ែត្រការ៉េ ១៥ (ដប់ប្រាំ) ដុល្លារអាមេរិក

សរុបទឹកប្រាក់ចំនួន ៧០.៣៥០ (ប្រាំពីរម៉ឺនបីរយហាសិប) ដុល្លារអាមេរិក ដោយចុងចម្លើយបានកក់ប្រាក់ចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាមេរិក នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ ដោយសន្យាប្រគល់ប្រាក់គ្រប់ចំនួននៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ តាមកិច្ចសន្យាទទួលប្រាក់កក់ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០។ លុះដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ ជាថ្ងៃកំណត់ប្រគល់ប្រាក់ បែរជាចុងចម្លើយមិនបានយកប្រាក់មកប្រគល់ឱ្យខ្ញុំបាទតាមការសន្យាដូចក្នុងកិច្ចសន្យាឡើយ ហើយចុងចម្លើយក៏មិនបានជូនដំណឹងមកខ្ញុំបាទស្តីពីការយឺតយ៉ាវឡើយ លុះរយៈពេលប្រហែល ១០ថ្ងៃ ក្រោយ ចុងចម្លើយបានទាក់ទងមកខ្ញុំបាទសុំប្រគល់ប្រាក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក មកប្រគល់ឱ្យខ្ញុំបាទ តែខ្ញុំបាទមិនព្រមទទួលយកនោះទេ ដោយខ្ញុំបាទសុំទាមទារប្រាក់គ្រប់ចំនួនតែម្តង។ លុះដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ចុងចម្លើយប្តឹងខ្ញុំបាទទៅសាលាឃុំ ដោយចុងចម្លើយសុំឱ្យខ្ញុំបាទលក់ដីឱ្យគាត់បន្ត តែខ្ញុំបាទមិនព្រម ហើយខ្ញុំបាទសុំផ្តាច់ប្រាក់កក់តែម្តង តែចុងចម្លើយមិនព្រម ទើបខ្ញុំបាទដាក់ពាក្យបណ្តឹងមកតុលាការសុំរំលាយកិច្ចសន្យាទទួលប្រាក់កក់នេះតែម្តង។ អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយបានអះអាងថាៈ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ ចុងចម្លើយបានស្នើសុំពន្យាពេលប្រគល់ប្រាក់បន្ថែមមកឱ្យខ្ញុំបាទនោះ គឺមិនពិតនោះទេ លុះដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ទើបចុងចម្លើយមកសុំបន្តកិច្ចសន្យា តែខ្ញុំបាទមិនព្រមនោះទេ ព្រោះកិច្ចសន្យាត្រូវបានផ្តាច់ហើយ ក្រោយមកនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ចុងចម្លើយបានប្តឹងទៅសាលាឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ដើម្បីចរចាសុំបន្តកិច្ចសន្យា ដោយការសម្របសម្រួលនោះខ្ញុំបាទមិនព្រម ខាងសាលាឃុំក៏បានបញ្ជាក់ថា បើខ្ញុំបាទមិនព្រមបន្តកិច្ចសន្យា ការសម្របសម្រួលមិនបាននោះទេ។ ខ្ញុំបាទស្នើសុំឱ្យតុលាការចេញសាលក្រមដូចខាងក្រោម៖

១-សុំរំលាយកិច្ចសន្យាទទួលប្រាក់កក់ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ រវាងឈ្មោះ [redacted] សល្យ និងឈ្មោះ [redacted] ចន្ថន។

២-ប្រាក់ពន្ធ និងប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

-លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ចន្ថន ធ្វើសេចក្តីថ្លែងការណ៍តបថាៈ ខ្ញុំបាទសុំរក្សាអង្គហេតុនៅក្នុងពាក្យបណ្តឹងតប ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ និងរក្សាការទាមទារតាមខ្លឹមសារនៃបណ្តឹងតបខាងលើទុកនៅដដែល។ ដោយនៅមុនថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ កូនក្តីខ្ញុំបាទធ្លាប់ជូនដំណឹងទាក់ទងនឹងការពន្យាពេលទូទាត់ប្រាក់ ក៏ដូចជាបានបញ្ជាក់អំពីចំនួនទឹកប្រាក់សម្រាប់ទូទាត់ជូនដើមចោទ គឺមិនទាន់គ្រប់ចំនួននោះទេនៅថ្ងៃកំណត់ ចំណែកដើមចោទក៏បានព្រមព្រៀងនឹងឯកភាពទៅតាមការជូនដំណឹងនេះ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ កូនក្តីខ្ញុំបាទក៏បានទាក់ទងមកដើមចោទយកលុយមកប្រគល់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក តែដើមចោទមិនព្រមនៅតែទាមទារចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក។ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០ កូនក្តីខ្ញុំបាទនៅតែបន្តយកប្រាក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ជូនទៅដើមចោទ តែដើមចោទនៅតែមិនព្រមដោយនៅតែទាមទារចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២០ កូនក្តីខ្ញុំបាទបានយកលុយចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ទៅប្រគល់ឱ្យដើមចោទដោយគាត់ព្រមទទួលតែមិនព្រមធ្វើឯកសារ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ដើមចោទបានទៅធ្វើកំណត់ហេតុជាមួយអាជ្ញាធរភូមិឃុំទាក់ទងនឹងការសុំរំលាយកិច្ចសន្យាកក់ប្រាក់ដោយឯកតោភាគី បន្ទាប់មកទៀត

របេឯប្រហែលមួយសប្តាហ៍ កូនក្តីខ្ញុំបាទបានទទួលដំណឹងថា ដើមចោទបានយកដីខាងលើទៅលក់ឱ្យអ្នកផ្សេងក្នុងតម្លៃ ១៨ (ដប់ប្រាំបី) ដុល្លារអាមេរិក ក្នុងមួយម៉ែត្រការ៉េ ដោយទទួលប្រាក់កក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ចំពោះការធ្វើកិច្ចសន្យាទិញលក់នេះផងដែរ តែអាជ្ញាធរភូមិឃុំមិនបានធ្វើកិច្ចសន្យានោះទេ។ ខ្ញុំបាទជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ចន្ទន ស្នើសុំឱ្យតុលាការចេញសាលក្រមដូចខាងក្រោម៖

១-បង្គាប់ឱ្យដើមចោទអនុវត្តកិច្ចសន្យាទទួលប្រាក់កក់ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ រវាងដើមចោទ និងចុងចម្លើយ។

២-បង្គាប់ឱ្យចុងចម្លើយធ្វើការទូទាត់ប្រាក់ថ្លៃដីដែលនៅសល់ចំនួន ៦៥.៣៥០ (ប្រាំមួយម៉ឺនបួនពាន់បីរយហាសិប) ដុល្លារអាមេរិក ឱ្យទៅភាគីដើមចោទ។

៣-បង្គាប់ឱ្យដើមចោទបន្ត និងអនុវត្តទៅតាមនីតិវិធីសុរិយោដីផ្ទេរកម្មសិទ្ធិ មានក្បាលដីលេខ: ២១១៥ ដែលមានទំហំ ៥.៦៩០ (បួនពាន់ប្រាំមួយរយកៅសិប) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិត្រពាំងសុភី ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ មកឱ្យចុងចម្លើយ។

**ចំណុចវិវាទ និងចំណុចគ្មានវិវាទ**

**-ចំណុចមានវិវាទ**

១-ដើមចោទសុំរំលាយកិច្ចសន្យាទទួលប្រាក់កក់ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ តែចុងចម្លើយស្នើសុំបន្តកិច្ចសន្យាទទួលប្រាក់កក់ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០។

២-ចុងចម្លើយសុំឱ្យដើមចោទធ្វើការទូទាត់ប្រាក់ថ្លៃដីដែលនៅសល់ចំនួន ៦៥.៣៥០ (ប្រាំមួយម៉ឺនបួនពាន់បីរយហាសិប) ដុល្លារអាមេរិក ឱ្យទៅភាគីដើមចោទ តែភាគីដើមចោទសុំបដិសេធ។

៣-ចុងចម្លើយស្នើសុំឱ្យដើមចោទបន្តអនុវត្តទៅតាមនីតិវិធីសុរិយោដីផ្ទេរកម្មសិទ្ធិ មានក្បាលដីលេខ: ២១១៥ ដែលមានទំហំ ៥.៦៩០ (បួនពាន់ប្រាំមួយរយកៅសិប) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិត្រពាំងសុភី ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ មកឱ្យចុងចម្លើយ តែដើមចោទសុំបដិសេធ។

**-ចំណុចគ្មានវិវាទ:**

-ប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តី។

***ភស្តុតាងដែលភាគីដើមចោទបានដាក់ជូនតុលាការពិនិត្យរួមមាន៖***

១-កិច្ចសន្យាទទួលប្រាក់កក់ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ រវាងឈ្មោះ [redacted] សល្យ និងឈ្មោះ ប៉ិច ចន្ទន។

២-កំណត់ហេតុ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០។

***ភស្តុតាងដែលភាគីចុងចម្លើយបានដាក់ជូនតុលាការពិនិត្យរួមមាន៖***

១-លិខិតស្នើសុំអន្តរាគមន៍ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] ចន្ទន។

២-កិច្ចសន្យាទទួលប្រាក់កក់ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ រវាងឈ្មោះ [redacted] សល្យ និងឈ្មោះ ប៉ិច ចន្ទន។

៣-លិខិតលក់ផ្តាច់ មានស្នាមមេដៃឈ្មោះ [redacted] សល្យ។

៤-ពាក្យស្នើសុំបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ។

៥-ពាក្យសុំចុះបញ្ជីអំពីការផ្ទេរសិទ្ធិ។



Scanned with CamScanner

៦-សេចក្តីព្រមព្រៀង និងអនុញ្ញាត។

៧-កិច្ចសន្យា។

៨-សំបុត្រគំណរវង្សត្រកូលនៃខ្មោច។

៩-សំបុត្របញ្ជាក់ទាយាទ។

១០-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ: ០៣០៧០៩២០៧ របស់ឈ្មោះ [redacted] សល្យ។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា៖

១-ពាក្យបណ្តឹង ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់ដើមចោទឈ្មោះ [redacted] សល្យ ភេទប្រុស អាយុ៦៧ឆ្នាំ ជនជាតិខ្មែរ មានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ ដែលអាចឱ្យតុលាការលើកយកមកធ្វើការទាញហេតុផលតាមបញ្ញត្តិមាត្រា ៩, មាត្រា ២៣ និងចេញសាលក្រមតាមបទបញ្ញត្តិមាត្រា ១៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២-ពាក្យបណ្តឹងតប ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ របស់លោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ចន្ថន ភេទប្រុស អាយុ៣៩ឆ្នាំ មានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ ដែលអាចឱ្យតុលាការលើកយកមកធ្វើការទាញហេតុផលតាមបញ្ញត្តិមាត្រា ៩, មាត្រា ២៣, មាត្រា ៨៦ និងចេញសាលក្រមតាមបទបញ្ញត្តិមាត្រា ១៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៣-ដើមចោទឈ្មោះ [redacted] សល្យ ភេទប្រុស អាយុ៦៧ឆ្នាំ ជនជាតិខ្មែរ បានទាមទាររំលាយកិច្ចសន្យាទទួលប្រាក់កក់ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ រវាងឈ្មោះ [redacted] សល្យ និងឈ្មោះ [redacted] ចន្ថន ដោយដើមចោទបានអះអាងថា ដើមចោទបានលក់ដី ទំហំ ៤.៦៩០ (បួនពាន់ប្រាំមួយរយកៅសិប) ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រពាំងសុភី ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ឱ្យទៅចុងចម្លើយឈ្មោះ [redacted] ចន្ថន ក្នុងតម្លៃ ០១ (មួយ) ម៉ែត្រការ៉េ ១៥ (ដប់ប្រាំ) ដុល្លារអាមេរិក ហើយចុងចម្លើយឈ្មោះ [redacted] ចន្ថន បានកក់ប្រាក់ចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាមេរិក ដោយសន្យាប្រគល់ប្រាក់គ្រប់ចំនួននៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ លុះដល់ថ្ងៃកំណត់ប្រគល់ប្រាក់ បែរជាចុងចម្លើយឈ្មោះ [redacted] ចន្ថន មិនបានយកប្រាក់មកប្រគល់ឱ្យដើមចោទតាមការព្រមព្រៀងនៅក្នុងកិច្ចសន្យាឡើយ ហើយចុងចម្លើយក៏មិនបានធ្វើការជូនដំណឹងមកដើមចោទស្តីពីការយឺតយ៉ាវដែរ លុះរយៈពេល ១០ ថ្ងៃ ក្រោយ ចុងចម្លើយបានយកប្រាក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក មកប្រគល់ឱ្យដើមចោទ តែដើមចោទមិនព្រមទទួលយកនោះទេ ដោយសុំឱ្យចុងចម្លើយប្រគល់ប្រាក់គ្រប់ចំនួន។ លុះដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ចុងចម្លើយបានប្តឹងដើមចោទទៅសាលាឃុំសុំឱ្យដើមចោទបន្តលក់ដីឱ្យទៅចុងចម្លើយ ដោយដើមចោទមិនព្រម គឺដើមចោទសុំផ្តាច់ប្រាក់កក់តែម្តង។

៤-ចុងចម្លើយឈ្មោះ [redacted] ចន្ថន ភេទប្រុស អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ បានទាមទារឱ្យដើមចោទអនុវត្តកិច្ចសន្យាទទួលប្រាក់កក់ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ រវាងឈ្មោះ [redacted] សល្យ និងឈ្មោះ [redacted] ចន្ថន ដោយចុងចម្លើយបានអះអាងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា ខ្លួនពិតជា

ទទួលស្គាល់ថា ខ្លួនពិតបានទិញដីមួយកន្លែង មានទំហំ ៤.៦៥០ (បួនពាន់ប្រាំមួយរយហាសិប) ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រពាំងសុភី ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ដោយបានធ្វើកិច្ចសន្យាកក់ប្រាក់ឱ្យទៅដើមចោទចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាមេរិក នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ ដូចដែលដើមចោទលើកឡើងប្រាកដមែន ហើយដល់ថ្ងៃកំណត់ប្រគល់ប្រាក់ចុងក្រោយ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ ខ្លួនពិតជាមិនបានប្រគល់ប្រាក់គ្រប់ចំនួនឱ្យទៅដើមចោទប្រាកដមែន។ តែនៅមុនពេលប្រហែល ១០ ថ្ងៃ ដល់ថ្ងៃកំណត់ប្រគល់ប្រាក់ ខ្លួនបានទាក់ទងទៅដើមចោទ ដោយសុំទៅដើមចោទពន្យារយៈពេលប្រហែល ១០ ថ្ងៃ ព្រោះខ្លួនទិញដីនេះឱ្យក្រុមហ៊ុន ហើយក្រុមហ៊ុនយកដីនេះទៅពុះឡូតិ៍លក់បន្តទៀត ដោយក្រុមហ៊ុននៅតែមិនមានប្រាក់គ្រប់ចំនួនដើម្បីទៅប្រគល់ឱ្យដើមចោទទៀត។ ក្រុមការងាររបស់ខ្លួនក៏បានជូនដំណឹងទៅសាលាឃុំភ្នំតូច ដើម្បីសម្របសម្រួលគ្នាឱ្យដើមចោទបន្តកិច្ចសន្យាបន្តទៀត តែដើមចោទមិនព្រមនោះទេ ដោយនៅតែសុំរំលាយកិច្ចសន្យាទទួលប្រាក់កក់នេះដដែល។ អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ ក៏បានអះអាងបន្ថែមថា នៅមុនថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ កូនក្តីខ្លួនធ្លាប់ជូនដំណឹងទាក់ទងនឹងការពន្យាពេលទូទាត់ប្រាក់ ក៏ដូចជាបានបញ្ជាក់អំពីចំនួនទឹកប្រាក់សម្រាប់ទូទាត់ជូនដើមចោទ គឺមិនទាន់គ្រប់ចំនួននោះទេនៅថ្ងៃកំណត់ ចំណែកដើមចោទក៏បានព្រមព្រៀងនឹងឯកភាពទៅតាមការជូនដំណឹងនេះ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ កូនក្តីខ្លួនក៏បានទាក់ទងមកដើមចោទយកលុយមកប្រគល់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក តែដើមចោទមិនព្រមនៅតែទាមទារចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក។ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០ កូនក្តីខ្លួននៅតែបន្តយកប្រាក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ជូនទៅដើមចោទ តែដើមចោទនៅតែមិនព្រម ដោយនៅតែទាមទារចំនួន ៤០.០០០ (បួនម៉ឺន) ដុល្លារអាមេរិក នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២០ កូនក្តីខ្លួនបានយកលុយចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ទៅប្រគល់ឱ្យដើមចោទ ដោយគាត់ព្រមទទួល តែមិនព្រមធ្វើឯកសារ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ដើមចោទបានទៅធ្វើកំណត់ហេតុជាមួយអាជ្ញាធរភូមិឃុំ ទាក់ទងនឹងការសុំរំលាយកិច្ចសន្យាកក់ប្រាក់ដោយឯកតោភាគី បន្ទាប់មកទៀតរំលងប្រហែលមួយសប្តាហ៍ កូនក្តីខ្លួនបានទទួលដំណឹងថា ដើមចោទបានយកដីខាងលើទៅលក់ឱ្យអ្នកផ្សេងក្នុងតម្លៃ ១៨ (ដប់ប្រាំបី) ដុល្លារអាមេរិក ក្នុងមួយម៉ែត្រការ៉េ ដោយទទួលប្រាក់កក់ ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ចំពោះការធ្វើកិច្ចសន្យាទិញលក់នេះផងដែរ គឺអាជ្ញាធរភូមិឃុំមិនបានធ្វើកិច្ចសន្យានោះទេ។

៥-តាមកិច្ចសន្យាទទួលប្រាក់កក់ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ និងតាមការអះអាងរបស់ដើមចោទ និងចុងចម្លើយ ឃើញថា ដើមចោទឈ្មោះ [redacted] សល្យ និងចុងចម្លើយឈ្មោះ [redacted] ចន្ថន ពិតជាបានធ្វើការលក់ទិញដី ទំហំ ៤.៦៥០ (បួនពាន់ប្រាំមួយរយហាសិប) ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រពាំងសុភី ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ក្នុងតម្លៃ ០១ (មួយ) ម៉ែត្រការ៉េ ១៥ (ដប់ប្រាំ) ដុល្លារអាមេរិក ដោយបានកក់ប្រាក់ចំនួន ៦.០០០ (ប្រាំមួយពាន់) ដុល្លារអាមេរិក និងបានសន្យាប្រគល់ប្រាក់គ្រប់ចំនួន នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ លុះដល់ថ្ងៃកំណត់ប្រគល់ប្រាក់ ចុងចម្លើយមិនបានប្រគល់ប្រាក់គ្រប់ចំនួនឱ្យទៅដើមចោទប្រាកដមែន។

៦-យោងតាមការអះអាងរបស់ដើមចោទថា ចុងចម្លើយមិនបានធ្វើការជូនដំណឹងមកដើមចោទស្តីពីការយឺតយ៉ាវនោះទេ និងមិនមានប្រាក់គ្រប់ចំនួនប្រគល់ឱ្យដើមចោទ ទើបដើមចោទសុំផ្តាច់ប្រាក់កក់

តែម្តង ហើយតាមការអះអាងរបស់ចុងចម្លើយ ក៏ដូចជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ ក៏មិនមានឯកសារជាភស្តុតាងណាមួយមកបញ្ជាក់ពីការជូនដំណឹងស្តីពីការយឺតយ៉ាវនេះដែរ។ លុះរយៈពេល ១០ ថ្ងៃក្រោយ នៃកាលបរិច្ឆេទផុតកំណត់សងប្រាក់ ចុងចម្លើយបានយកប្រាក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក មកប្រគល់ឱ្យដើមចោទ តែដើមចោទមិនព្រមទទួលយកនោះទេ ដោយសុំឱ្យចុងចម្លើយប្រគល់ប្រាក់គ្រប់ចំនួន។ ចុងចម្លើយក៏បានបញ្ជាក់បន្ថែមថា ដល់ថ្ងៃកំណត់ប្រគល់ប្រាក់ចុងក្រោយ នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ ខ្លួនពិតជាមិនបានប្រគល់ប្រាក់គ្រប់ចំនួនឱ្យទៅដើមចោទប្រាកដមែន និងតាមអះអាងរបស់អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយថា រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ដើមចោទបានទៅធ្វើកំណត់ហេតុជាមួយអាជ្ញាធរភូមិឃុំ ទាក់ទងនឹងការសុំរំលាយកិច្ចសន្យាកក់ប្រាក់ដោយឯកតោភាគី ត្រង់ចំណុចនេះបញ្ជាក់ថា ចុងចម្លើយពិតជាបានទទួលដំណឹងស្តីពីការរំលាយកិច្ចសន្យា ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ រវាងដើមចោទ និងចុងចម្លើយរួចរាល់ហើយ។

៧-ទង្វើរបស់ចុងចម្លើយ គឺជាការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ព្រោះថាដើមចោទបានដាស់តឿនឱ្យចុងចម្លើយយកប្រាក់មកប្រគល់ឱ្យដើមចោទគ្រប់ចំនួន ដោយចុងចម្លើយនៅតែមិនបានយកប្រាក់គ្រប់ចំនួនមកប្រគល់ឱ្យដើមចោទនោះទេ ដោយបានយកប្រាក់តែចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក មកប្រគល់ឱ្យដើមចោទ ហើយដើមចោទមិនព្រមទទួលយកឡើយ ដោយចុងចម្លើយមិនព្រមអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនឡើយ ដូច្នេះដើមចោទអាចរំលាយកិច្ចសន្យាទទួលប្រាក់កក់បានស្របតាមមាត្រា ៤០៧ និងមាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី។

៨-ការរំលាយកិច្ចសន្យានាំឱ្យភាគីមានករណីយកិច្ចសងតាវកាលិកឱ្យទៅភាគីម្ខាងទៀត ហេតុដូច្នេះ ចុងចម្លើយមានករណីយកិច្ចប្រគល់ដី ទំហំ ៤.៦៥០ (បួនពាន់ប្រាំមួយរយហាសិប) ម៉ែត្រការ៉េ ស្ថិតនៅភូមិត្រពាំងសុភី ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ឱ្យទៅដើមចោទវិញ តាមមាត្រា ៤១១ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី។

៩-តាមពាក្យបណ្តឹងតប ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ របស់លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ចន្ថន ស្នើសុំទាមទារបង្គាប់ឱ្យដើមចោទអនុវត្តកិច្ចសន្យាទទួលប្រាក់កក់ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ រវាងដើមចោទ និងចុងចម្លើយ, បង្គាប់ឱ្យចុងចម្លើយធ្វើការទូទាត់ប្រាក់ថ្លៃដីដែលនៅសល់ចំនួន ៦៤.៣៥០ (ប្រាំមួយម៉ឺនបួនពាន់បីរយហាសិប) ដុល្លារអាមេរិក ឱ្យទៅភាគីដើមចោទ និងបង្គាប់ឱ្យដើមចោទបន្ត និងអនុវត្តទៅតាមនីតិវិធីសុរិយោដីផ្ទេរកម្មសិទ្ធិ មានក្បាលដីលេខ: ២១១៥ ដែលមានទំហំ ៤.៦៥០ (បួនពាន់ប្រាំមួយរយហាសិប) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិត្រពាំងសុភី ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ មកឱ្យចុងចម្លើយ តែដើមចោទមិនព្រមដោយសុំផ្តាច់កិច្ចសន្យា ព្រោះចុងចម្លើយបានបំពានកិច្ចសន្យា និងមិនបានអនុវត្តកាតព្វតាមកាលកំណត់នៅក្នុងកិច្ចសន្យា ហេតុដូច្នេះ គប្បីតុលាការច្រានចោលការទាមទារនៅក្នុងពាក្យបណ្តឹងតបរបស់អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយតាមច្បាប់។

១០-ចំពោះប្រាក់ប្រដាប់ក្តី គប្បីតុលាការសម្រេចតាមមាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី "ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់ភាគីចាញ់ក្តី"។ ក្នុងករណីដែលបានចាញ់ក្តីតែមួយភាគទេ តុលាការត្រូវសម្រេចនូវបន្ទុកដែលភាគីម្នាក់ៗ ត្រូវទទួលដោយឆន្ទានុសិទ្ធិរបស់ខ្លួន។

**សេចក្ដីសម្រេចបញ្ចប់**

I-រំលាយកិច្ចសន្យាទទួលប្រាក់កក់ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ រវាងដើមចោទឈ្មោះ [redacted] សល្យ និងចុងចម្លើយឈ្មោះ [redacted] ចន្ថន។

II-ច្រានចោលការទាមទារក្នុងពាក្យបណ្ដឹងតប ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ របស់លោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] ចន្ថន ទាំងស្រុង។

III-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃពុធ ១៥កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង ០៩ និង ១០ នាទី ព្រឹក។

បើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ចៅក្រមជំនុំជម្រះ**

[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១៥កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅកំពង់ស្ពឺ, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]